សាលាអន្តរជាតិ
បាមប៊ូចាយ៉ា

BAMBUJAYA
INTERNATIONAL SCHOOL

# កម្មវិធីសិក្សាថ្នាក់មត្តេយ្យនៅបាមប៊ូចាយ៉ា

## ការរៀនធ្វើការទំនាក់ទំនងនិងការអនុវត្តតាមរយៈការសហការគ្នា ការធ្វើត្រាប់តាម ការលេង និងទម្លាប់ប្រចាំថ្ងៃ

នៅថ្នាក់មត្តេយ្យ ក្មេងៗធ្វើការសង្កេតដោយយកចិត្តទុកដាក់ និងចូលចិត្តធ្វើត្រាប់តាម ដូច្នេះវាជាពេលវេលាដ៏ល្អបំផុតដើម្បីបង្រៀននូវទម្លាប់ល្អៗ និងការផ្តល់តម្លៃដែលទាំងនេះនឹងនៅស្ថិតស្ថេរក្នុងជីវិតរបស់គាត់។ ក្មេងៗចាប់អារម្មណ៍នូវអ្វីដែលមនុស្សពេញវ័យកំពុងធ្វើ និងចង់មាននូវអ្វីដែលខ្លួនឯងចង់ធ្វើ ហើយពេលវេលានឹងផ្តល់ឱកាសឲ្យពួកគេធ្វើការស្វែងយល់ពីពិភពលោកនិងអភិវឌ្ឍការស្រមើស្រមៃឲ្យកាន់តែប្រសើរ។ បន្ទាប់មក ពួកគេនឹងធ្វើការរួមបញ្ចូលការជឿងឆ្ងល់ជាមួយនឹងការយល់ពីសហគមន៍របស់ពួកគេក្នុងការផ្តល់ដំណោះស្រាយចំពោះបញ្ហាផ្សេងៗដែលកើតមានឡើង។

ដោយការយល់ដឹងយ៉ាងច្បាស់លាស់ពីការអប់រំតាមរយៈការធ្វើដោយដៃ ដោយចិត្ត និងដោយគំនិតប្រាជ្ញា បាមប៊ូចាយ៉ាផ្តល់ឱកាសនិងពេលវេលាគ្រប់គ្រាន់ដល់សិស្សានុសិស្សក្នុងការអភិវឌ្ឍជំនាញ អារម្មណ៍ និងចំណេះដឹងរបស់ពួកគេទៅតាមអាយុដែលសមស្រប។ នៅក្នុងកម្មវិធីសិក្សាថ្នាក់មត្តេយ្យរបស់យើង យើងផ្តល់ភាពកក់ក្តៅនិងសោភ័ណ្ឌភាពនៅក្នុងថ្នាក់រៀន សម្ភារលេង សិល្បៈ និងបរិស្ថានបែបធម្មជាតិដែលនាំអោយជីវិតគាត់មានភាពស្រស់បំព្រង។

ក្មេងៗរៀនពីភាសាផ្សេងៗ គណិតវិទ្យា ជំនាញសង្គមនិងការអនុវត្តតាមរយៈការលេង ការបំពេញការងារ និងការសហការ
ហើយនៅក្នុងបរិយាកាសដែលប្រកបទៅដោយភាពរីករាយស្វាគមន៍រួមជាមួយនឹងទម្លាប់ប្រចាំថ្ងៃនិងសកម្មភាពប្រចាំសប្តាហ៍មួយចំនួនទៀតដូចជាការដុតនំ ការចម្អិនម្ហូបអាហារ ការផាត់ពណ៌ហត្ថកម្ម ការលេងល្បែងកម្សាន្តក្នុងនិងក្រៅថ្នាក់ និងការធ្វើការសម្អាតជាកត្តាជម្រុញអោយក្មេងៗមានការលូតលាស់យ៉ាងល្អប្រសើរទាំងផ្នែករាងកាយនិងប្រាជ្ញាស្មារតី។

ក្រោយពីបញ្ចប់កម្មវិធីសិក្សាឆ្នាំទីមួយនៅក្នុងថ្នាក់មត្តេយ្យសិស្សានុសិស្សនឹងអាច៖

### ជំនាញភាសា

- អាចឆ្លើយតបនៅពេលមានអ្នកហៅឈ្មោះពួកគេ និងធ្វើតាមការណែនាំងាយៗនៅពេលបំពេញកិច្ចការជាក្រុម
- ស្តាប់ និងធ្វើតាមការណែនាំងាយៗទាំងពីរភាសា
- ស្តាប់អ្នកដទៃ និងអាចរង់ចាំវេនរបស់ខ្លួនដើម្បីនិយាយ
- ប្រើប្រាស់ការបញ្ចេញសម្លេងពាក្យជាភាសាខ្មែរ និងអង់គ្លេស

- សូត្រកំណាព្យ និងច្រៀងចម្រៀងដោយប្រើដៃ ការធ្វើកាយវិកា និងការធ្វើចលនា
- ការទំនាក់ទំនង និងប្រាប់ពីតម្រូវការផ្ទាល់ខ្លួន

**ជំនាញក្នុងការរាប់លេខ និងដំណោះស្រាយ**

- រាប់លេខតាមសកម្មភាពប្រចាំថ្ងៃជាភាសាខ្មែរ និងអង់គ្លេសពី១ដល់១០
- ការកត់សម្គាល់ពីវត្ថុផ្សេងៗដែលនៅកន្លែងខុសគ្នា
- ស្គាល់/អនុវត្តតាមលំដាប់លំដោយទៅតាមកិច្ចការ ដូចជាការរៀបចំអាហារសម្រន់ ឬការលាងដៃ

**ជំនាញផ្នែកសង្គម និងអារម្មណ៍**

- ងាយស្រួលក្នុងការបំបែកពីក្រុមគ្រួសារ ដូចជាការនាំមកសាលារៀនជាដើម
- លេងដោយភាពឯករាជ្យពីមនុស្សចាស់
- មានការសង្កេត មានសុជីវធម៌ល្អ មានទម្លាប់ប្រចាំថ្ងៃ និងចាប់ផ្តើមមានការឆ្លើយតមដោយសមស្រប
- ចាប់ផ្តើមមានការអត់ធ្មត់ក្នុងការរងចាំដល់វេនខ្លួនឯងដើម្បីធ្វើកិច្ចការផ្សេងៗ
-

**បំណិនជីវិត និងការប្រើប្រាស់កាយសម្បទា**

- អនុវត្តការធ្វើអនាម័យល្អដោយមានជំនួយពីមនុស្សធំ
- ជួយការងារប្រចាំថ្ងៃ និងជួយរៀបចំពេលបរិភោគអាហារដោយមានជំនួយពីមនុស្សធំ
- អភិវឌ្ឍការសហការរវាងដៃនិងភ្នែកតាមរយៈរៀបចំណីអាហារ ចម្រៀងមានកាយវិកា កំណាព្យ
- អភិវឌ្ឍការធ្វើការរួមគ្នា និងការរក្សាលំនឹងលើរាងកាយតាមរយៈការលេងនៅខាងក្រៅ ការឡើងចុះ ការរត់ ការជីករុករក និងការដេរប៉ាក់
- អាចឆ្លើយតមទៅនឹងទម្លាប់ប្រចាំថ្ងៃ រួមជាមួយនឹងការផ្លាសប្តូរពីការធ្វើកិច្ចការទៅជាពេលបរិភោគអាហារ
- ស្វែងយល់ពីរបៀបគ្រប់គ្រងតម្រូវការផ្ទាល់ខ្លួនរបស់ពួកគេ

ក្រោយពីបញ្ចប់កម្មវិធីសិក្សាថ្នាក់មត្តេយ្យនិងមុនឈានចូលកម្រិតថ្នាក់ទី១ សិស្សានុសិស្សនឹងអាចៈ

**ជំនាញភាសា**

- ស្តាប់ និងធ្វើតាមការណែនាំងាយៗជាភាសាខ្មែរ និងអង់គ្លេស
- ស្តាប់អ្នកដទៃ និងអាចរង់ចាំវេនរបស់ខ្លួនដើម្បីនិយាយ
- រៀន និងអនុវត្តការប្រើប្រាស់ពាក្យតាមរយៈសកម្មភាពប្រចាំថ្ងៃជាភាសាខ្មែរ និងអង់គ្លេស
- ប្រើប្រាស់ការបញ្ចេញសម្លេងពាក្យជាភាសាខ្មែរ និងអង់គ្លេស
- កត់សម្គាល់សម្លេងព្យញ្ជនៈតាមរយៈការស្តាប់និងការនិយាយ
- និយាយឈ្មោះពេញលេញ
- សូត្រកំណាព្យ និងច្រៀងចម្រៀងដោយឯករាជ្យ
- ការទំនាក់ទំនង ប្រាប់ពីតម្រូវការផ្ទាល់ខ្លួន ចែករំលែកគំនិត និងនិទានរឿងឡើងវិញ ព្រមទាំងដើរតួសម្តែងជាមួយប្រដាប់ប្រដាលេងរបស់ប្អូនៗ

**ជំនាញក្នុងការរាប់លេខ និងដំណោះស្រាយ**

- រាប់លេខដើម្បីចូលរួមសកម្មភាពប្រចាំថ្ងៃជាភាសាខ្មែរ និងអង់គ្លេសពី១ដល់២០
- ចាប់ផ្តើមយល់ពីចំនួននិងសារៈសំខាន់របស់វា
- ធ្វើការបែងចែករបស់ផ្សេងៗគ្នាទៅតាមក្រុម
- កត់សម្គាល់ការសរសេរលេខ
- ដឹងពីលំនាំនិងជំហានក្នុងការអនុវត្តកិច្ចការងាយៗដោយឯករាជ្យភាព

**ជំនាញផ្នែកសង្គម និងអារម្មណ៍**

- បង្ហាញការគោរព ការយល់ចិត្ត និងការយកចិត្តទុកដាក់លើអ្នកដទៃ
- បង្ហាញពីភាពឯករាជ្យនៅក្នុងទម្លាប់ប្រចាំថ្ងៃ
- ធ្វើការសហការជាមួយអ្នកដទៃដើម្បីសម្រេចកិច្ចការ
- បង្ហាញការស្រឡាញ់និងថែទាំថ្នាក់រៀនអោយល្អប្រសើរ
- មានអាកប្បកិរិយាល្អ
- អនុវត្តការគ្រប់គ្រងខ្លួនឯង និងគ្រប់គ្រងតម្រូវការបុគ្គល
- មានទំនុកចិត្តលើខ្លួនឯងនិងសមត្ថភាពក្នុងការបំពេញកិច្ចការងាយៗ

**បំណិនជីវិត និងការប្រើប្រាស់កាយសម្បទា**

- អនុវត្តការធ្វើអនាម័យល្អដោយភាពឯករាជ្យ
- ជួយរៀបចំមុននិងក្រោយពេលអាហារ រួមជាមួយការជួយច្របាច់ម្សៅ និងហាន់បន្លែ
- ជួយធ្វើការសម្អាតប្រចាំថ្ងៃ រួមជាមួយការជួយលាងចាន ការជូតសម្អាតតុ ការជួយបោសជូតថ្នាក់រៀន និងរាបរបស់លេងដាក់តាមកន្លែង
- អភិវឌ្ឍការសហការរវាងដៃនិងភ្នែកតាមរយៈការដេរប៉ាក់ ការកៃច្នៃ ការផាត់ពណ៌ និងការប្រើប្រាស់ក្រមួនធ្វើជារូបផ្សេងៗដែលមានលំនាំច្បាស់លាស់
- អភិវឌ្ឍការធ្វើការរួមគ្នា និងការរក្សាលំនឹងលើរាងកាយតាមរយៈការលេងនៅខាងក្រៅ ការឡើងចុះ ការរត់ និងការជីករុករក
- អនុវត្តសកម្មភាពប្រចាំថ្ងៃដូចជាការរៀបចំទុកដាក់ និងការសម្អាត